# របាយការណ៍វឌ្ឍនភាពរបស់ការិយាល័យ ស៊ីអេអូ
# ករណី Cambodia Veil II-01/ខេត្តរតនគិរី
# ខែធ្នូ ឆ្នាំ២០១៩

*របាយការណ៍នេះផ្តល់នូវទិដ្ឋភាពរួមអំពីដំណើរការដោះស្រាយវិវាទរបស់ការិយាល័យ ស៊ីអេអូ ទាក់ទងនឹងពាក្យបណ្តឹងចំពោះគម្រោង VEIL II ដែលបានទទួលកិច្ចគាំទ្រពីសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC #20926) ក្នុងប្រទេសកម្ពុជា។*

## សង្ខេប

ចាប់តាំងពីខែមីនា ឆ្នាំ២០១៤ រហូតដល់ខែមករា ឆ្នាំ ២០១៩ ការិយាល័យ ស៊ីអេអូ បានចាប់ផ្តើមដំណើរការដោះស្រាយវិវាទមួយ រវាងក្រុមហ៊ុនហ៊ែងអានយ៉ាឡាយ (HAGL) ដែលជាប្រតិបត្តិករចំការកៅស៊ូរបស់វៀតណាម នៅក្នុងខេត្តរតនគិរីនៃព្រះរាជាណាចក្រកម្ពុជា និង ភូមិក្នុងមូលដ្ឋានដែលរងផលប៉ះពាល់ ដើម្បីដោះស្រាយបញ្ហាកង្វល់អំពីផលប៉ះពាល់ផ្នែកបរិស្ថាន និង សង្គមដែលបង្កឡើងដោយចំការទាំងនេះ។ គូភាគីសម្រេចបានការឯកភាពព្រមព្រៀងបឋមជាច្រើន និងបានស្វែងរកកិច្ចគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា ដែលបានបង្កើតឱ្យមាននូវក្រុមការងារចម្រុះថ្នាក់ខេត្តមួយក្រុម ដើម្បីគាំទ្រដល់ដំណើរការនេះ។

កន្លងមក មានកិច្ចព្រមព្រៀងគួរឱ្យកត់សម្គាល់មួយចំនួនដែលបានឯកភាពគ្នា ទាក់ទងនឹងការប្រគល់ដីត្រឡប់មកវិញ ការស្តារប្រព័ន្ធផ្លូវទឹក និងការជួសជុលផ្លូវ។ ការិយាល័យ ស៊ីអេអូ បាន និង កំពុងត្រួតពិនិត្យការអនុវត្តកិច្ចព្រមព្រៀងទាំងនេះ ហើយគិតមកទល់នឹងពេលបច្ចុប្បន្ន ការអនុវត្តកិច្ចព្រមព្រៀងទាំងនេះមានកម្រិតវិសាលភាពផ្សេងៗគ្នា។ កាលពីខែមករា ឆ្នាំ ២០១៩ ក្រុមហ៊ុនបានសម្រេចចិត្តដកខ្លួនចេញពីដំណើរការសន្ទនានេះ ដោយបានបង្ហាញឱ្យដឹងថាក្រុមហ៊ុនមានបំណងចង់មើលឃើញរដ្ឋាភិបាល ជួយដល់ការដោះស្រាយបញ្ហាដែលនៅសេសសល់ជំនួសវិញ។

កាលពីខែតុលា ឆ្នាំ២០១៩ ក្រុមហ៊ុនហ៊ែងអានយ៉ាឡាយ បានបង្ហាញអំពីចំណាប់អារម្មណ៍ ក្នុងការចូលរួមនៅក្នុងកិច្ចសន្ទនានេះវិញ។ ការិយាល័យ ស៊ីអេអូ បានជួបជាមួយក្រុមហ៊ុនហ៊ែងអានយ៉ាឡាយ និង សហគមន៍ដើមបណ្តឹងដាច់ដោយឡែកពីគ្នាកាលពីខែធ្នូ ឆ្នាំ២០១៩ ហើយភាគីទាំងសងខាងបានបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការដោះស្រាយបញ្ហាវិវាទដែលនៅសេសសល់ តាមរយៈដំណើរការដោះស្រាយវិវាទដែលរៀបចំឡើងដោយការិយាល័យ ស៊ីអេអូ។

## សាវតានៃបណ្តឹង

**ការវិនិយោគរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC)**

សហគ្រាសវិនិយោគវៀតណាមចំកាត់ ("VEIL" ឬ "មូលនិធិ") គឺជាមូលនិធិវិនិយោគមួយ ដែលបាននិងកំពុងមានប្រតិបត្តិការចាប់តាំងពីឆ្នាំ១៩៩៥។ មូលនិធិនេះមានមូលដ្ឋានមូលធនរបស់ខ្លួនតែជាង ៥០០ លាន ដុល្លារអាមេរិកប៉ុណ្ណោះ និង គ្រប់គ្រងដោយក្រុមហ៊ុនដ្រេហ្គិន ខាភីថល ម៉ាណេជមិន ចំកាត់ ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ ដ្រេហ្គិន ខាភីថល គ្រុប (DCG)។ IFC បានវិនិយោគមូលនិធិចំនួន ១៦,៤លាន ដុល្លារអាមេរិក។ មូលនិធិនេះមានគោលបំណងវិនិយោគលើមូលប័ត្រសាធារណៈ ឬ ឯកជនរបស់ក្រុមហ៊ុនវៀតណាម ដើម្បីផ្តល់ការលើកទឹកចិត្តសម្រាប់ការអភិវឌ្ឍទីផ្សារមូលធនវៀតណាមតាមរយៈការបង្កើនសាច់ប្រាក់របស់មូលប័ត្រវៀតណាម។ ក្នុងចំណោមបណ្តាក្រុមហ៊ុននានាដែល DCG បានវិនិយោគតាមរយៈមូលនិធិនេះ គឺក្រុមហ៊ុនហ៊ែងអានយ៉ាឡាយ។

## ពាក្យបណ្តឹង

កាលពីខែកុម្ភៈ ឆ្នាំ២០១៤ ប្រជាពលរដ្ឋមូលដ្ឋាននៃភូមិចំនួន ១៧ ក្នុងខេត្តរតនគិរី ព្រះរាជាណាចក្រកម្ពុជា បានដាក់ពាក្យបណ្តឹងមួយទៅការិយាល័យ ស៊ីអេអូ ដោយមានកិច្ចគាំទ្រ និង ជំនួយពីអង្គការមិនមែនរដ្ឋាភិបាលថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និង អន្តរជាតិចំនួន៥។ ពាក្យបណ្តឹងបានលើកឡើងនូវបញ្ហាកង្វល់ផ្នែកបរិស្ថាន និង សង្គមមួយចំនួន ទាក់ទងនឹងប្រតិបត្តិការរបស់ក្រុមហ៊ុនហ៊ាងអានយ៉ាឡាយ ក្នុងប្រទេសកម្ពុជា ក្នុងនោះរួមមានផលប៉ះពាល់ទៅលើប្រភពទឹក និងធនធានជលផល ការបាត់បង់ដីដូនតា និងដីជនជាតិដើមភាគតិច ការឈូសឆាយព្រៃឈើខុសច្បាប់ និងផលប៉ះពាល់ពាក់ព័ន្ធទៅលើជីវភាពរស់នៅ កង្វះការផ្តល់សំណង កង្វះការផ្តល់ព័ត៌មាន និង ការគោរពសិទ្ធិផ្តល់ការយល់ព្រមដោយសេរីជាមុន និងក្រោមមូលដ្ឋាននៃព័ត៌មានគ្រប់ជ្រុងជ្រោយរបស់ជនជាតិដើមភាគតិច ការគំរាមកំហែងចំពោះការប្រតិបត្តិផ្នែកអារក្ស វប្បធម៌ និងការប្រតិបត្តិដទៃទៀតរបស់ជនជាតិដើមភាគតិច ព្រមទាំងការប្រើប្រាស់ពលកម្មកុមារ។ ពាក្យបណ្តឹងបានចោទប្រកាន់ អំពីភាពមិនអនុលោមទៅនឹងគោលនយោបាយ និងនីតិវិធីរបស់ IFC ព្រមទាំងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា។ ដើមបណ្តឹង បានស្នើសុំឱ្យការិយាល័យ ស៊ីអេអូ រក្សាអត្តសញ្ញាណរបស់ ពួកគេជាការសម្ងាត់។



*ព្រៃឈើត្រូវបានឈូសឆាយ ដើម្បីត្រៀមរៀបចំដាំដុះសម្រាប់ប្រតិបត្តិការរបស់ក្រុមហ៊ុនហ៊ាងអានយ៉ាឡាយ ក្នុងខេត្តរតនគិរី*

# ដំណើរការរបស់ការិយាល័យ ស៊ីអេអូ

## ការប៉ាន់ប្រមាណ

ដើមបណ្តឹងត្រូវបានកំណត់ថាមានលក្ខខណ្ឌសមស្របសម្រាប់ធ្វើការប៉ាន់ប្រមាណបន្ថែមទៀតក្នុងខែកុម្ភៈ ឆ្នាំ២០១៤ ដោយក្រុមការងាររបស់ការិយាល័យ ស៊ីអេអូ បានធ្វើដំណើរចុះទៅសិក្សានៅឯមូលដ្ឋាន ក្នុងខែមីនា ឆ្នាំ២០១៤ ដើម្បីជួបជាមួយអ្នកពាក់ព័ន្ធនានា ដើម្បីស្វែងរកជម្រើសសម្រាប់ដំណោះស្រាយមួយបែបសហការ ចំពោះបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង។ សហគមន៍បានលើកឡើងនូវបញ្ហាកង្វល់អំពីផលប៉ះពាល់បច្ចុប្បន្ន និងអនាគត ទៅលើជីវភាពរស់នៅ និងសិទ្ធិរបស់ពួកគេ។ ក្រុមហ៊ុនហ៊ាងអានយ៉ាឡាយ បានប្តេជ្ញាដោះស្រាយបញ្ហាកង្វល់នានា និង យកប្រយោជន៍របស់សហគមន៍ជាអាទិភាព។ ក្នុងខែមេសា ឆ្នាំ២០១៤ គូភាគីបានបង្ហាញឱ្យឃើញអំពីឆន្ទៈរបស់ពួកគេក្នុងការចូលរួមនៅក្នុងដំណើរការដោះស្រាយវិវាទបែបស្ម័គ្រចិត្តមួយរបស់ការិយាល័យ ស៊ីអេអូ។

## ដំណើរការដោះស្រាយវិវាទបានចាប់ផ្តើម

### ការផ្អាកការឈូសឆាយបន្ត

នៅពេលចាប់ផ្តើមដំណើរការដំបូង ក្រុមហ៊ុនហ៊ាងអានយ៉ាឡាយ បានយល់ព្រមឈប់ឈូសឆាយដីបន្ថែមទៀតនៅក្នុងបរិវេណដីសម្បទានរបស់ខ្លួនរយៈពេល៦ខែ ដើម្បីអនុញ្ញាតឱ្យដំណើរការសន្ទនាវិវឌ្ឍន៍ទៅមុខ។ ក្រោយរយៈពេល៦ខែនេះ ក្រុមហ៊ុនបានប្តេជ្ញាបន្តការផ្អាកឈូសឆាយរហូតដល់ពេលដែលពួកគេអាចដោះស្រាយវិវាទ ជាមួយសហគមន៍ជិតខាងបាន។ នៅពេលក្រោយមកទៀតនៅក្នុងដំណើរការនេះ កាលពីខែកញ្ញា ឆ្នាំ២០១៥ ក្រុមហ៊ុនហ៊ាងអានយ៉ាឡាយ បានជូនដំណឹងដល់បណ្តាភូមិនានាថា ពួកគេនឹងប្រគល់ត្រឡប់មកវិញនូវរាល់ផ្ទៃដីទាំងអស់ ដែលមិនទាន់បានឈូសឆាយ ឬ ដាំដុះ ជូនទៅរដ្ឋាភិបាលវិញ និង ស្នើសុំឱ្យធ្វើការកែសម្រួលទៅលើសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន។

ក្រោយមក សម្បទានដីសេដ្ឋកិច្ចទាំងបីក្រុមហ៊ុននេះ ត្រូវបានកាត់បន្ថយជាផ្លូវការពី ១៨.៩៥២ ហិកតា មកត្រឹម ៨.៣៧១ ហិកតា។

## ការរៀបចំត្រៀមលក្ខណៈសម្រាប់សន្ទានកម្ម

នៅចន្លោះខែឧសភា និង ខែសីហា ឆ្នាំ២០១៤ ការិយាល័យ ស៊ីអេអរ្ អូ បានរៀបចំឱ្យមានវគ្គបុរេសន្ទានកម្មមួយចំនួនជាមួយ គូភាគី ដើម្បីរៀបចំគូភាគីសម្រាប់ជំនួសសន្ទនា។ ក្នុងអំឡុង ពេលនេះ ការិយាល័យ ស៊ីអេអូ បានគាំទ្រដល់សហគមន៍ ក្នុង ការកំណត់រកអ្នកតំណាងសហគមន៍ និង ការខិតខំបង្កើត លក្ខណៈឱ្យមានការចូលរួមពីរដ្ឋាភិបាលពាក់ព័ន្ធគ្រប់កម្រិត។



*ក្រុមការងារនៃការិយាល័យ ស៊ីអេអូ ជួបជាមួយឯ.ឧ. ញ៉ែម សំអឿន អភិបាលរងខេត្តរតនគិរី និង លោក សេក ហៃ នាយករដ្ឋបាលនៃ សាលាខេត្តរតនគិរី ព្រះរាជាណាចក្រកម្ពុជា ក្នុងខែវិច្ឆិកា ឆ្នាំ២០១៥*

## ការធានាឱ្យបាននូវកិច្ចគាំទ្រពីរដ្ឋាភិបាល

គូភាគីបានស្វែងរក និង ត្រូវការឱ្យមានកិច្ចគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា សម្រាប់ដំណើរការនេះ។ ដូច្នេះ ការិយាល័យ ស៊ីអេអូ បានជួបជាមួយមន្ត្រីសំខាន់ៗនៅឯក្រសួងគ្រប់គ្រងដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ក្រសួងមហាផ្ទៃ សាលាខេត្តរតនគិរី និងមន្ទីរពាក់ព័ន្ធ ដើម្បីជូនដំណឹងដល់ពួកគេអំពីដំណើរការនេះ ព្រមទាំងសុំកិច្ចគាំទ្រពីពួកគេផងដែរ។ ក្នុងខែវិច្ឆិកា ឆ្នាំ២០១៤ ការិយាល័យ ស៊ីអេអូ បានទទួលលិខិតមួយច្បាប់ពីក្រសួងមហាផ្ទៃ ដែលបញ្ជាក់អំពីកិច្ចគាំទ្ររបស់ក្រសួងចំពោះដំណើរការរបស់ការិយាល័យ ស៊ីអេអូ។

## ការកសាងសមត្ថភាព

ដោយមានកិច្ចគាំទ្រពីរាជរដ្ឋាភិបាល ដំណើរការដោះស្រាយវិវាទ បានចាប់ផ្ដើមក្នុងខែវិច្ឆិកា ឆ្នាំ២០១៤ ជាមួយនឹងការផ្ដល់ការកសាងសមត្ថភាពជូនដល់ភាគី អំពីយន្តការដោះស្រាយវិវាទ និងបច្ចេកទេសចរចារ។ បន្ថែមពីនេះទៀត ការិយាល័យ ស៊ីអេអូ បានផ្ដល់កិច្ចគាំទ្រក្នុងដំណើរការទាំងមូល នៅក្នុងកិច្ចប្រជុំទ្វេភាគីជាមួយគូភាគី។ ទន្ទឹមនឹងនេះដែរ អង្គការតំណាងរបស់សហគមន៍ ក៏បានផ្ដល់កិច្ចគាំទ្រដល់អ្នកតំណាងសហគមន៍ ព្រមទាំងបានជួយដល់ពួកគេឱ្យចូលរួមក្នុងដំណើរការនេះ។

## ភាពជាតំណាង

កាលពីខែធ្នូ ឆ្នាំ២០១៤ សហគមន៍រងផលប៉ះពាល់នីមួយៗ បានជ្រើសរើសអ្នកតំណាង សម្រាប់ភូមិរបស់ពួកគេរៀងៗខ្លួន តាមរយៈកិច្ចប្រជុំភូមិមួយចំនួន ដោយមានការចូលរួមពីក្រុមការងារនៃការិយាល័យ ស៊ីអេអូ។ ភូមិនីមួយៗបានជ្រើសរើសអ្នកតំណាងមួយក្រុមធំ ដែលមានអ្នកតំណាងប្រមាណ៩រូប និងក្នុងចំណោមនោះ រួមមានអ្នកតំណាងចម្បងចំនួន២រូប សម្រាប់ចូលរួមកិច្ចប្រជុំនានា។

## វិធានមូលដ្ឋាន

កិច្ចប្រជុំរួមគ្នាលើកដំបូងរវាងគូភាគី ដើម្បីរៀបចំដំណើរការចរចារ បានធ្វើឡើងក្នុងខែមករា ឆ្នាំ២០១៥ ដោយក្នុងពេលនោះ គូភាគីបានឯកភាព និង ចុះហត្ថលេខាទទួលយកកម្រងវិធានមូលដ្ឋានមួយចំនួន សម្រាប់ជាមគ្គុទ្ទេសក៍ណែនាំនៅក្នុងដំណើរការសន្ទានកម្មនេះ។

## ការឯកភាពទៅលើរចនាសម្ព័ន្ធនៃដំណើរការ

ខណៈពេលដែលដំណើរការសន្ទានកម្មមានការវិវឌ្ឍន៍ទៅមុខ គូភាគីអាចមានលទ្ធភាពផ្ដល់ការបញ្ជាក់បានកាន់តែច្បាស់អំពីភូមិជាក់ស្ដែងដែលរងផលប៉ះពាល់ដោយគម្រោងរបស់ក្រុមហ៊ុនហ៊ាងអានយ៉ាឡាយ។ ដូច្នេះ សហគមន៍ត្រូវបានរៀបចំចងក្រងជាបីក្រុម៖

- ក្រុមទី១៖ ភូមិចំនួន៣ ដែលមិនរងផលប៉ះពាល់ដោយក្រុមហ៊ុនហ៊ាងអានយ៉ាឡាយ និង ស្ថិតនៅក្រៅតំបន់សម្បទានដីសេដ្ឋកិច្ច។
- ក្រុមទី២៖ ភូមិចំនួន៣ ត្រូវបានរកឃើញថាស្ថិតនៅក្នុងសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនហ៊ាងអានយ៉ាឡាយ ប៉ុន្តែមិនទាន់រងផលប៉ះពាល់នៅឡើយ។ ក្រោយមក មានការបញ្ជាក់ច្បាស់លាស់ថា ភូមិមួយក្នុងចំណោមភូមិទាំង៣ នេះ នៅមានការទាមទាដីដែលត្រួតគ្នាទៅនឹងដីសម្បទានរបស់ក្រុមហ៊ុន ដូច្នេះភូមិមួយនោះក៏ត្រូវបានដាក់បញ្ចូលទៅក្នុងភូមិក្រុមទី៣ សម្រាប់បន្តដំណើរការសន្ទានកម្ម។

- ក្រុមទី៣៖ ភូមិចំនួន១១ ដែលបានរងផលប៉ះពាល់រួចទៅហើយដោយសកម្មភាពរបស់ក្រុមហ៊ុនហ៊ងអានយ៉ាឡាយ។

កាលពីខែមីនា ឆ្នាំ២០១៥ គូភាគីបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយដើម្បីសម្របសម្រួលដោះស្រាយវិវាទ និង បានចេញសេចក្តីថ្លែងការណ៍រួមជាលើកដំបូង ដែលកំណត់ចែងអំពីរចនាសម្ព័ន្ធនៃដំណើរការសន្ទានកម្ម។ ចាប់តាំងពីពេលនោះមក ការិយាល័យ ស៊ីអេអូ បានរៀបចំឱ្យមានកិច្ចប្រជុំសន្ទានកម្មជាទៀងទាត់រវាងគូភាគី។ មានកិច្ចព្រមព្រៀងផ្សេងៗគ្នា ដែលសម្រេចបានជាបន្តបន្ទាប់ ដោយគូភាគីបានដាក់បញ្ចូលទៅក្នុងសេចក្តីថ្លែងការណ៍រួម ដែលសេចក្តីថ្លែងការណ៍រួមទាំងនេះអាចរកមើលបាននៅក្នុងគេហទំព័ររបស់ការិយាល័យ ស៊ីអេអូ ៖ www.cao-ombudsman.org។

## តួនាទីរបស់អង្គការតំណាង

អង្គការមិនមែនរដ្ឋាភិបាលចំនួន៥ បានគាំទ្រសហគមន៍ក្នុងការដាក់ពាក្យបណ្តឹងទៅការិយាល័យ ស៊ីអេអូ និង នៅក្នុងដំណើរការនេះ ក្នុងនោះរួមមានជាអាទិ៍៖ សមាគមខ្មែរលើ សមាគមន៍យុវជនជនជាតិដើមភាគតិចកម្ពុជា សមាជិកសកម្មសិទ្ធិជនជាតិដើមភាគតិច អង្គការសមធម៌កម្ពុជា និង អង្គការ Inclusive Development International ។ អង្គការមិនមែនរដ្ឋាភិបាលបានជួយដល់សហគមន៍ ក្នុងការចូលរួមនៅក្នុងដំណើរការនេះ ឧទាហរណ៍ដូចជា ការរៀបចំត្រៀមលក្ខណៈសម្រាប់កិច្ចប្រជុំរួមគ្នា ការរៀបចំត្រៀមលក្ខណៈដើម្បីបង្ហាញអំពីសេចក្តីត្រូវការរបស់ពួកគេ ការស្វែងយល់អំពីគោលជំហររបស់ក្រុមហ៊ុន ការប្រកាន់គោលជំហររួមគ្នា និង ការកសាងសមត្ថភាពរបស់អ្នកតំណាងសហគមន៍ជាទូទៅ ដើម្បីតំណាងឱ្យខ្លួនឯង និង ចូលរួមនៅក្នុងដំណើរការសន្ទានកម្ម។

## កិច្ចព្រមព្រៀងបឋម

### ភូមិក្រុមទី១ ដែលមិនរងផលប៉ះពាល់ដោយផ្ទាល់ពីសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនហ៊ងអានយ៉ាឡាយ

ការផ្លោះប្តូរព័ត៌មានរវាងគូភាគី បានជួយកំណត់ថាមានភូមិចំនួន៣នៅក្នុងពាក្យបណ្តឹង មិនរងផលប៉ះពាល់ដោយផ្ទាល់ពីប្រតិបត្តិការរបស់ក្រុមហ៊ុនហ៊ងអានយ៉ាឡាយ។ តាមរយៈសេចក្តីថ្លែងការណ៍រួមលើកទី២ ដែលចេញផ្សាយក្នុងខែកក្កដា ឆ្នាំ២០១៥ មានភូមិចំនួន៣ បានប្រាប់ឱ្យដឹងថាពួកគេលែងស្ថិតនៅក្នុងដំណើរការនេះទៀតហើយ និង ម្យ៉ាងវិញទៀត ក្រុមហ៊ុនបានប្តេជ្ញាមិនពាក់ព័ន្ធនៅក្នុងការអភិវឌ្ឍតំបន់ដែលពួកគេកាន់កាប់ឡើយ នៅពេលអនាគត។

### ក្រុមហ៊ុនហ៊ងអានយ៉ាឡាយ បានធ្វើការប្តេជ្ញាចិត្តមួយចំនួន

កាលពីខែកញ្ញា ឆ្នាំ២០១៥ ក្រុមហ៊ុនបានធ្វើការប្តេជ្ញាចិត្តមួយចំនួន ក្នុងនោះរួមមានការមិនចូលរួមនៅក្នុងការឈូសឆាយ ឬ ការអភិវឌ្ឍបន្ថែមទៀតទៅលើតំបន់សម្បទានរបស់ខ្លួន ដើម្បីជៀសវាងបង្កផលប៉ះពាល់អវិជ្ជមានបន្ថែមទៀត ទៅលើភូមិទាំង ១១។ ការប្តេជ្ញាចិត្តទាំងនេះ បានត្រួសត្រាយផ្លូវឱ្យមានការឯកភាពព្រមព្រៀងបន្ថែមទៀត ជាមួយភូមិចំនួន៣ទៀត ដែលស្ថិតនៅក្នុងតំបន់សម្បទានរបស់ក្រុមហ៊ុនដែរ ប៉ុន្តែនឹងមិនរងផលប៉ះពាល់ ដោយសារតែក្រុមហ៊ុនបានប្តេជ្ញាមិនធ្វើការឈូសឆាយ និងអភិវឌ្ឍទៅលើដីបន្ថែមទៀត។

កិច្ចព្រមព្រៀងរវាងគូភាគី បានកំណត់ចេញនូវផែនការសម្រាប់ដំណើរទស្សនកិច្ចរួមគ្នាមួយទៅមូលដ្ឋាន ដើម្បីឱ្យសហគមន៍ និងក្រុមហ៊ុន អាចបញ្ជាក់អំពីព្រំប្រទល់ដីរបស់ពួកគេ ព្រមទាំងបានកំណត់ផងដែរនូវការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុនហ៊ងអានយ៉ាឡាយ ក្នុងការបង្កើតយន្តការបណ្តឹងសារទុក្ខមួយសម្រាប់សហគមន៍ដាក់ពាក្យបណ្តឹង ពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ខ្លួនក្នុងប្រទេសកម្ពុជា (សេចក្តីថ្លែងការរួមទី៣ ចេញក្នុងខែកញ្ញា ឆ្នាំ២០១៥)។

បន្ថែមពីនេះទៀត កាលពីខែកញ្ញា ឆ្នាំ២០១៥ នៅឯកិច្ចប្រជុំរួមមួយដែលធ្វើឡើងក្នុងខេត្តសៀមរាប ក្រុមហ៊ុន និង សហគមន៍ទាំង១១ដែលរងផលប៉ះពាល់ដោយផ្ទាល់ខ្លាំងបំផុតបានឈានដល់ការឯកភាពលើកិច្ចព្រមព្រៀងមួយចំនួន សម្រាប់ក្រុមភូមិទាំងនេះ ក្នុងនោះរួមមានផែនការធ្វើដំណើរទស្សនកិច្ចរួមគ្នា ទៅតាមបណ្តាភូមិនានាដើម្បីកំណត់រកដីវិវាទ ការស្តារប្រភពទឹកឡើងវិញ ការជួសជុលផ្លូវ និងស្ពាន ព្រមទាំងការយល់ព្រមផ្តល់សំណង ឬ ប្រគល់ដីត្រឡប់មកវិញ ក្នុងករណីដែលក្រុមហ៊ុនហ៊ងអានយ៉ាឡាយបានឈូសឆាយ ឬ អភិវឌ្ឍទៅលើដីរបស់សហគមន៍ (សេចក្តីថ្លែងការណ៍រួមទី៤ ចេញក្នុងខែកញ្ញា ឆ្នាំ២០១៥)។

### កិច្ចព្រមព្រៀងខេត្តសៀមរាប

- ក្រុមហ៊ុនហ៊ងអានយ៉ាឡាយនឹងប្រើផលិតផលគីមីដែលស្របតាមលិខិតបទដ្ឋានគតិយុត្តិផ្នែកបរិស្ថានប៉ុណ្ណោះ ។
- ក្រុមហ៊ុនហ៊ងអានយ៉ាឡាយ នឹងជួសជុល និងថែទាំផ្លូវ និង ស្ពានដែលអ្នកភូមិប្រើ ដែលទទួលរងផលប៉ះពាល់ដោយសារប្រតិបត្តិការរបស់ក្រុមហ៊ុនហ៊ងអានយ៉ាឡាយ ។
- គូភាគី និងអ្នកពាក់ព័ន្ធដទៃទៀត រួមមានអង្គការតំណាង ការិយាល័យ ស៊ីអេអូ និងអាជ្ញាធរមូលដ្ឋាន នឹងធ្វើទស្សនកិច្ចរួមគ្នា ទៅភូមិនីមួយៗទាំង១១ ដើម្បីកំណត់រកព្រំប្រទល់ចំការរបស់ក្រុមហ៊ុនហ៊ងអានយ៉ាឡាយ និងព្រំប្រទល់របស់ភូមិរងផលប៉ះពាល់ ក្នុងគោលបំណងធ្វើការកំណត់ព្រំប្រទល់។
- ប្រសិនបើតាមរយៈដំណើរទស្សនកិច្ចរួមគ្នា បញ្ជាក់ថា ក្រុមហ៊ុនហ៊ងអានយ៉ាឡាយ បានឈូសឆាយ និងអភិវឌ្ឍន៍ដីដែលជាកម្មសិទ្ធិរបស់អ្នកភូមិ នោះក្រុមហ៊ុននឹង (ក) ផ្តល់សំណងដល់អ្នកភូមិសម្រាប់ដីនេះ និង (ខ) ប្រសិនបើអ្នកភូមិមិនព្រមទទួលយកសំណងទេ ក្រុមហ៊ុនហ៊ងអានយ៉ាឡាយ នឹងប្រគល់ដីជូនអ្នកភូមិវិញ ព្រមទាំងផ្តល់ការគាំទ្រដល់អ្នកភូមិក្នុងការស្នើសុំប្លង់កម្មសិទ្ធិដីរបស់ពួកគេ។
- ក្រុមហ៊ុនហ៊ងអានយ៉ាឡាយ នឹងស្តារឡើងវិញនូវប្រភពទឹកដែលរងផលប៉ះពាល់ រួមទាំងធនធានត្រីដែលបានបាត់បង់ សម្រាប់ភូមិទាំង ១៤ ដែលបានចូលរួមក្នុងដំណើរការដោះស្រាយវិវាទរបស់ការិយាល័យ ស៊ីអេអូ (រួមមានភូមិទាំង ១១ ខាងលើ និង ភូមិកេត ភូមិណាយ និង ភូមិកាដូត )។
- ដោយទទួលស្គាល់អំពីផលប៉ះពាល់ដែលបង្កដោយគម្រោងចំការកៅស៊ូរបស់ក្រុមហ៊ុន ក្រុមហ៊ុនហ៊ងអានយ៉ាឡាយសូមខមារទោសដោយស្មោះ ចំពោះភូមិទាំង ១៤ និងសូមផ្តល់ជូនគោមួយក្បាល (ទម្ងន់ ៤០០ គីឡូក្រាម) និងថវិកា ៥០០ ដុល្លារអាមេរិក ដល់ភូមិនីមួយៗ សម្រាប់ប្រើប្រាស់ក្នុងពិធីសែនព្រេនអារក្ស។

## ការអនុវត្តកិច្ចព្រមព្រៀងបឋម

### ពិធីសូមខមាទោស និងការឧបត្ថម្ភសម្រាប់ពិធីនេះ

ដើម្បីចាប់ផ្តើមការអនុវត្តកិច្ចព្រមព្រៀងបឋម គូភាគី អង្គការតំណាង និង អ្នកតំណាងមកពីរដ្ឋាភិបាលថ្នាក់ខេត្ត ព្រមទាំងក្រុមការងារនៃការិយាល័យ ស៊ីអេអូ បានចូលរួមនៅក្នុងពិធីសែនព្រេនមួយ នាថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥។ ក្រុមហ៊ុនហ៊ងអានយ៉ាឡាយ បានសូមខមាទោសជាសាធារណៈចំពោះសហគមន៍ជនជាតិដើមភាគតិច សម្រាប់ផលប៉ះពាល់ដែលបានបង្កឡើងទៅលើពួកគេ និងរបៀបផែនជីវិតរស់នៅរបស់ពួកគេ។



*អ្នកតំណាងសហគមន៍ ការិយាល័យ ស៊ីអេអូ ក្រុមហ៊ុន និងរាជរដ្ឋាភិបាលកម្ពុជា ចូលរួមពិធីសែនព្រេន ខែវិច្ឆិកា ឆ្នាំ២០១៥*

### ដំណើរទស្សនកិច្ចទៅមូលដ្ឋានដើម្បីបញ្ជាក់អំពីព្រំប្រទល់ដី

កាលពីខែមករា ឆ្នាំ២០១៦ គូភាគីបានជួបគ្នាដើម្បីពិភាក្សាអំពីការអនុវត្ត "កិច្ចព្រមព្រៀងខេត្តសៀមរាប" និង រៀបចំផែនការធ្វើដំណើរកំណត់ផែនទីរួមគ្នា ទៅភូមិរងផលប៉ះពាល់នីមួយៗ ដើម្បីកំណត់ព្រំប្រទល់សម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនហ៊ងអានយ៉ាឡាយ (សេចក្តីថ្លែងការរួមទី៥ ខែមករា ឆ្នាំ២០១៦)។

នៅចន្លោះខែមករា ឆ្នាំ២០១៦ និង ខែកក្កដា ឆ្នាំ២០១៧ អ្នកតំណាងក្រុមហ៊ុន និងអ្នកតំណាងសហគមន៍ សមាជិករដ្ឋាភិបាលថ្នាក់ខេត្ត អង្គការតំណាង និង ក្រុមការងារនៃការិយាល័យ ស៊ីអេអូ បានធ្វើដំណើររួមគ្នាជាច្រើនដង ទៅភូមិដែលរងផលប៉ះពាល់ ដើម្បីកំណត់រកតំបន់ផ្ទៃដីវិវាទ។ ភាគីនីមួយៗបានផ្តល់នូវអ្នកជំនាញខាងកំណត់ផែនទីរបស់ពួកគេរៀងៗខ្លួន។

នៅក្នុងដំណើរទស្សនកិច្ចរួមគ្នាលើកដំបូង គូភាគីបានបញ្ជាក់ថាមានភូមិចំនួនពីរស្ថិតនៅក្រៅព្រំប្រទល់សម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនហ៊ាងអានយ៉ាឡាយ។ បើទោះជាដូច្នេះក្តី ភូមិទាំងពីរនេះ បានសម្រេចចិត្តបន្តចូលរួមជាមួយក្រុមហ៊ុនតាមរយៈដំណើរការសន្ទានកម្មដែលសម្របសម្រួលដោយការិយាល័យ ស៊ីអេអូ លើបញ្ហាដទៃទៀត ដូចមានឯកភាពកាលពីខែកញ្ញា ឆ្នាំ២០១៥ (សូមមើលសេចក្តីថ្លែងការណ៍រួម ទី៤)។ សេចក្តីថ្លែងការណ៍រួម ទី៦ (កក្កដា ២០១៦) សង្ខេបអំពីលទ្ធផលនៃដំណើរទស្សនកិច្ចរួមគ្នានេះ។

## ក្រុមការងាររបស់រដ្ឋាភិបាល

ក្នុងខែតុលា ឆ្នាំ២០១៦ រដ្ឋាភិបាលបានបង្កើតក្រុមការងារចម្រុះមួយ ដើម្បីជួយដល់គូភាគីក្នុងការកំណត់រកតំបន់ត្រួតគ្នារវាងសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនហ៊ាងអានយ៉ាឡាយ និងដីដែលសហគមន៍ជនជាតិដើមភាគតិចប្រើប្រាស់តាមបែបប្រពៃណី។ ចាប់ពីពេលនោះមក រដ្ឋាភិបាលបានចូលរួមនៅក្នុងដំណើរការសម្របសម្រួលដោះស្រាយវិវាទ តាមរយៈក្រុមការងារនេះ ទៅតាមសំណើរបស់គូភាគី ដើម្បីជួយដល់ពួកគេក្នុងការស្វែងរកដំណោះស្រាយមួយប្រកបដោយសន្តិវិធី។

## កិច្ចព្រមព្រៀងក្នុងការប្រគល់ភ្នំអារក្ស និងដីកប់សពមកវិញ

ក្នុងខែកក្កដា ឆ្នាំ២០១៧ បន្ទាប់ពីមានកិច្ចប្រជុំមួយចំនួនដែលសម្របសម្រួលដោយការិយាល័យ ស៊ីអេអូ អ្នកតំណាងភូមិរងផលប៉ះពាល់ទាំង១១ ក្រុមហ៊ុនហ៊ាងអានយ៉ាឡាយ និង អង្គការតំណាង បានចេញសេចក្តីថ្លែងការណ៍រួមមួយ ដែលកំណត់ចែងអំពីកិច្ចព្រមព្រៀងបន្ថែម រួមមាន ការប្រគល់ភ្នំអារក្សត្រឡប់មកវិញ និង ការអនុវត្តកិច្ចព្រមព្រៀងពីមុន ដើម្បីស្តារប្រភពទឹក និងផ្លូវថ្នល់ (សេចក្តីថ្លែងការណ៍រួម ទី៧)។

គូភាគីបានឯកភាពសហការជាមួយរដ្ឋាភិបាល ដើម្បីបង្កលក្ខណៈឱ្យមានការអនុវត្តសេចក្តីថ្លែងការរួមឱ្យបានពេញលេញ។ បន្ថែមពីនេះទៀត គូភាគីបានឯកភាពថា ទីតាំង ទំហំ និងព្រំប្រទល់ភ្នំអារក្ស និង ដីកប់សព នឹងត្រូវកំណត់រួមគ្នាដោយសហគមន៍ និងក្រុមហ៊ុនហ៊ាងអានយ៉ាឡាយ ក្រោមកិច្ចគាំទ្រ និង ការអនុម័តពីរដ្ឋាភិបាលខេត្តរតនគិរី តាមរយៈដំណើរការកំណត់ព្រំប្រទល់រួមគ្នាមួយ។

ចំពោះទីតាំងដែលគ្មានការឯកភាពគ្នារវាងគូភាគី ដំណោះស្រាយគឺរដ្ឋាភិបាលជាអ្នកធ្វើការសម្រេចចិត្តថាទីតាំងទាំងនោះនឹងត្រូវប្រគល់ ឬ មិនប្រគល់ទៅឱ្យសហគមន៍។

ក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ អភិបាលខេត្តរតនគិរី បានចេញលិខិតបង្គាប់ការតែងតាំងក្រុមការងារចម្រុះមួយដែលរួមមានសមាសភាពមន្ត្រីចំនួន ៧រូប មកពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មន្ទីរកសិកម្ម រុក្ខប្រមាញ់ និងនេសាទ មន្ទីរបរិស្ថាន និងទីចាត់ការអន្តរវិស័យនៃសាលាខេត្តរតនគិរី ដើម្បីគាំទ្រ និង អនុវត្តសកម្មភាពនេះ។



*មន្ត្រីនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ កំពុងយកចំណុច ជីភីអែស ក្នុងអំឡុងពេលនៃដំណើរការកំណត់ព្រំប្រទល់ ខែមីនា ឆ្នាំ២០១៨*

## ដំណើរការកំណត់ព្រំប្រទល់ដីរួមគ្នា

នៅចន្លោះខែវិច្ឆិកា រហូតដល់ខែធ្នូ ឆ្នាំ២០១៧ អ្នកតំណាងភូមិទាំង១២ ក្រុមហ៊ុនហ៊ាងអានយ៉ាឡាយ ក្រុមការងារចម្រុះរបស់រដ្ឋាភិបាល អង្គការតំណាង និង ក្រុមការងារនៃការិយាល័យ ស៊ីអេអូ បានអនុវត្តដំណើរការកំណត់ព្រំប្រទល់ដីរួមគ្នាលើកដំបូង ក្នុងគោលបំណងកំណត់រកភ្នំអារក្ស ដីកប់សព *ច្រប់* (កន្លែងដែលមានទឹកចេញពេញមួយឆ្នាំ និង សម្បូរទៅដោយបន្លែ ត្រី។ល។) និង *ត្រពាំង*? 

ការកំណត់ព្រំប្រទល់ដីលើកទី២ ត្រូវបានធ្វើឡើងក្នុងខែមីនា ឆ្នាំ២០១៨ ដែលនាំឱ្យទទួលបានទីតាំងដែលបានវាស់វែងសរុបចំនួន ៤៦កន្លែង ក្នុងនោះរួមមានភ្នំអារក្សចំនួន ២១ កន្លែងកប់សពចំនួន៨ *ប្រេប*ចំនួន១៤ និង*ព្រាយ*ចំនួន៣។ រាល់គ្រប់ចំណុចជីភីអេសទាំងអស់ ត្រូវបានសម្រេចរួមគ្នាដោយគូភាគីក្រោមជំនួយពីសន្ទានការីនៃការិយាល័យ ស៊ីអេអូ។

បន្ទាប់ពីបញ្ចប់ដំណើរការកំណត់ព្រំប្រទល់រួចរាល់ ក្រុមហ៊ុន ហ៊ាងអានយ៉ាឡាយ បានយល់ព្រមប្រគល់ភ្នំអារក្សចំនួន ២០ និង ដីកប់សពចំនួន២កន្លែង ទៅឱ្យសហគមន៍គ្រប់គ្រងវិញ។ បើទោះជាដូច្នេះក្តី សហគមន៍បានបង្ហាញអំពីការរំពឹងទុករបស់ពួកគេថារាល់ទីតាំងទាំង ៤៦ កន្លែង ដែលបានវាស់វែងរួច នឹងត្រូវបានប្រគល់មកឱ្យពួកគេវិញ។

ក្រុមការងាររបស់រដ្ឋាភិបាល បានរៀបចំរបាយការណ៍តារាងទិន្នន័យមួយក្រោយពេលកំណត់ព្រំប្រទល់រួចរាល់ ដោយបានកំណត់ថាមាន ៦៤ក្បាលដី លើទីតាំងដីចំនួន ៤៦កន្លែង ដែលបានវាស់វែងដោយឧបករណ៍ ជីភីអេស។ ផ្ទៃដីសរុបដែលបានវាស់វែងដំបូង មានទំហំ ១.០២៣,៧៦ ហិកតា។ ក្រុមការងារបានវិភាគទិន្នន័យ ដោយកាត់ផ្ទៃដីដែលបានទាមទារ និងបានកំណត់ព្រំប្រទល់រួចរាល់ ដែលស្ថិតនៅក្រៅបរិវេណសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហ៊ាងអានយ៉ាឡាយ។ បន្ទាប់មកក្រុមការងារ បានសន្និដ្ឋានថាផ្ទៃដីដែលបានវាស់វែង និងស្ថិតនៅក្នុងសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហ៊ាងអានយ៉ាឡាយ មានទំហំ ៧៤២,២៦ ហិកតា។ ក្រុមការងារក៏បានគណនារកឃើញផ្ទៃដីចំនួន ១៦៩ហិកតា ដែលបានវាស់វែងរួច ប៉ុន្តែក្រុមហ៊ុនមិនចង់ប្រគល់ត្រឡប់ទៅឱ្យសហគមន៍វិញ ដោយភាគច្រើនគឺដោយសារតែតំបន់ផ្ទៃទាំងនេះបានធ្វើការដាំដុះរួចរាល់។

## ពិធីមួយដែលប្រារព្ធធ្វើឡើងដោយរដ្ឋាភិបាលថ្នាក់ខេត្ត

នៅចុងខែមីនា ឆ្នាំ២០១៩ រដ្ឋាភិបាលថ្នាក់ខេត្តបានធ្វើការផ្សព្វផ្សាយជាសាធារណៈអំពីសេចក្តីសម្រេចរបស់ខ្លួន ដោយបានផ្តល់អនុសាសន៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឱ្យប្រគល់ត្រឡប់មកវិញនូវរាល់ផ្ទៃដីដែលបានចុះវាស់វែង ដែលមានទំហំសរុប ៧៤២.២៦ហិកតា។ ការប្រគល់ត្រឡប់មកវិញនូវភ្នំមួយដែលបានដាំដុះរួចរាល់មួយផ្នែក នៅពេលចប់រយៈពេលសម្បទានដីសេដ្ឋកិច្ច ត្រូវបានលើកយកមកពិភាក្សា។ នៅឯពិធីមួយ ដែលប្រារព្ធធ្វើឡើងនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩ ឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្តរតនគិរី បានអញ្ជើញអ្នកតំណាងភូមិ ក្រុមហ៊ុនហ៊ាងអានយ៉ាឡាយ រដ្ឋាភិបាលថ្នាក់ខេត្ត និងការិយាល័យ ស៊ីអេអូ ឱ្យចូលរួមដើម្បីផ្តល់បច្ចុប្បន្នភាពជូនដល់គូភាគីអំពីលទ្ធផលនៃដំណើរការកំណត់ព្រំប្រទល់ និង អបអរសាទរអ្នកគ្រប់គ្នាចំពោះវឌ្ឍនភាពដែលសម្រេចបាន។

កាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ ឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្តរតនគិរី បានដាក់សំណើទៅក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ ស្នើសុំឱ្យកាត់ផ្ទៃដីចំនួន ៧៤២,២៦ ហិកតា ពីសម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហ៊ាងអានយ៉ាឡាយ។

ដោយមានសំណើពីរដ្ឋាភិបាល ការិយាល័យ ស៊ីអេអូ កំពុងគាំទ្រដល់ដំណើរការដឹកនាំដោយរដ្ឋាភិបាល ដែលមានការចូលរួមពីរដ្ឋបាលខេត្តរតនគិរី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធដទៃទៀត ដើម្បីពិនិត្យសម្រេច និងអនុវត្តការប្រគល់ដីត្រឡប់មកវិញ។ ដំណើរការនេះកំពុងបន្ត។

## ការអនុវត្តកិច្ចព្រមព្រៀងកន្លងមក

ក្នុងខែឧសភា ឆ្នាំ២០១៨ អ្នកតំណាងភូមិទាំង១២ ក្រុមហ៊ុន ហ៊ាងអានយ៉ាឡាយ ក្រុមការងារចម្រុះរបស់រដ្ឋាភិបាល មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្តរតនគិរី និង មន្ទីរបរិស្ថាន បានពិភាក្សាគ្នាអំពីជម្រើសសម្រាប់ដោះស្រាយបញ្ហាកង្វល់ទាក់ទងនឹងដីធ្លី និង ការអនុវត្តកិច្ចព្រមព្រៀងកន្លងមក ទាក់ទងនឹងការជួសជុលស្ពាន និងផ្លូវ និងការស្តារឡើងវិញនូវប្រភពទឹក។

នៅក្នុងកិច្ចប្រជុំនេះ គូភាគីបានពិនិត្យឡើងវិញទៅលើទិន្នន័យដែលទទួលបានពីការកំណត់ផែនទីដោយប្រើឧបករណ៍ជីភីអេស ដែលបានកត់ត្រានៅក្នុងដំណើរការកំណត់ព្រំប្រទល់ ហើយគូភាគីបានឯកភាពថា ទិន្នន័យនេះឆ្លុះបញ្ចាំងយ៉ាងសុក្រឹត្យ

ចំពោះរាល់ទីតាំងដែលបានកំណត់ព្រំប្រទល់។ សហគមន៍ និង ក្រុមហ៊ុនក៏បានយល់ព្រមធ្វើការវាស់វែងកំណត់ផ្លូវចេញចូល ទៅកាន់តំបន់ដែលនឹងត្រូវប្រគល់ឱ្យសហគមន៍វិញផងដែរ។

## ការស្តារផ្លូវថ្នល់ និងផ្លូវទឹកឡើងវិញ

ក្រុមហ៊ុនហ៊ាងអានយ៉ាឡាយ បានប្តេជ្ញាអនុវត្តធ្វើការជួសជុល ផ្លូវដែលបានឯកភាពកន្លងមក ដោយសហការជាមួយ សហគមន៍មូលដ្ឋាន។ បើទោះបីជាក្រុមហ៊ុនបានដោះស្រាយ ធ្វើការជួសជួលផ្លូវមួយចំនួនក៏ដោយ ប៉ុន្តែសហគមន៍បាន បង្ហាញឱ្យឃើញអំពីក្តីកង្វល់ចំពោះគុណភាពនៃការជួសជុល និងកង្វះការពិគ្រោះយោបល់នៅក្នុងដំណើរការជួសជុលនេះ។ កិច្ចព្រមព្រៀងស្តារឡើងវិញនូវផ្លូវទឹកត្រូវបានជម្រុញ តាមរយៈ ការប្តេជ្ញាចិត្តរបស់ក្រុមហ៊ុនក្នុងការរក្សាឱ្យមានជំនាញឯកទេស ពាក់ព័ន្ធ។ បើទោះជាដូច្នេះក្តី ចាប់ពីពេលដែលក្រុមហ៊ុន ហ៊ាង អានយ៉ាឡាយ បានដកខ្លួនពីកិច្ចសន្ទនាដែលរៀបចំដោយ ការិយាល័យ ស៊ីអេអូ មក ការអនុវត្តការប្តេជ្ញាចិត្តទាំងនេះហាក់ បីដូចជាបានផ្អាកទៅវិញ។

ឥឡូវនេះ ការចូលរួមរបស់ក្រុមហ៊ុនហ៊ាងអានយ៉ាឡាយនៅក្នុង ដំណើរការនេះជាថ្មីម្តងទៀត នឹងបង្កលក្ខណៈឱ្យភាគីអាច ពិភាក្សា និង រៀបចំផែនការអនុវត្តកិច្ចព្រមព្រៀងដែលមាន ស្រាប់របស់ពួកគេ។

## តួនាទីរបស់ IFC ក្នុងនាមជាអ្នកសង្កេតការណ៍ចំពោះដំណើរការ នេះ

IFC បានបញ្ជូនអ្នកសង្កេតការណ៍មួយរូប ឱ្យធ្វើការសង្កេត ដំណើរការនេះនៅដំណាក់កាលផ្សេងៗគ្នា រួមទាំងនៅក្នុង ដំណើរដើម្បីពិភាក្សាអំពីការស្តារផ្លូវទឹក និង តំបន់ដីសើមឡើង វិញ កាលពីខែធ្នូ ឆ្នាំ២០១៨ ផងដែរ។ អ្នកសង្កេតការណ៍បាន គាំទ្រដល់ភាគី តាមរយៈការចែករំលែកជំនាញឯកទេសផ្នែក បរិស្ថានរបស់គាត់។

## ការដកខ្លួនរបស់ក្រុមហ៊ុនពីដំណើរការដោះស្រាយវិវាទរបស់ ការិយាល័យ ស៊ីអេអូ

ក្នុងឱកាសនៃកិច្ចប្រជុំវគ្គដំបូង នៃអ្វីដែលបានគ្រោងថាជាការ ចរចារលើកចុងក្រោយ រវាងសហគមន៍ និងក្រុមហ៊ុនហ៊ាងអាន យ៉ាឡាយ លើបញ្ហាដែលនៅសេសសល់ ក្រុមហ៊ុនហ៊ាងអាន យ៉ាឡាយ បានដកខ្លួនចេញពីដំណើរការសន្ទានកម្មនេះ និង បានបង្ហាញឱ្យដឹងថា ពួកគេចង់ឱ្យរដ្ឋាភិបាលកម្ពុជាធ្វើការ សម្រេចចិត្ត ដើម្បីដោះស្រាយបញ្ហាដែលនៅសេសសល់ជំនួស វិញ។ បញ្ហាដែលនៅសេសសល់ទាំងនេះ ពាក់ព័ន្ធនឹងតំបន់ផ្ទៃ ដីដទៃទៀត ដែលសហគមន៍បានទាមទារ ប៉ុន្តែមិនទាន់បាន កំណត់ព្រំប្រទល់នៅឡើយ ហើយសហគមន៍ទាមទារឱ្យមាន ការផ្តល់សំណងសម្រាប់ការខូចខាតនានាដែលបានកើតឡើង។

## បណ្តឹងថ្មី

បន្ទាប់ពីក្រុមហ៊ុន ហ៊ាងអានយ៉ាឡាយ បានដកខ្លួនពីកិច្ចសន្ទនា ដែលរៀបចំដោយការិយាល័យ ស៊ីអេអូ មក សហគមន៍បាន ដាក់បណ្តឹងថ្មីមួយទៅការិយាល័យ ស៊ីអេអូ អំពីប្រតិបត្តិការ របស់ក្រុមហ៊ុន ហ៊ាងអានយ៉ាឡាយ នៅក្នុងខេត្តរតនគិរី ដោយ បណ្តឹងលើកនេះ ពាក់ព័ន្ធទៅនឹងអតិថិជនអន្តរការីហិរញ្ញវត្ថុ របស់ IFC ពោលគឺ ធនាគារទៀនផុង ខមមឺសល ចញ ស្តុក (TPBank) និង ធនាគារវៀតណាម ប្រ៉ូស្ព័ររីធី ចញ ស្តុក ខមមឺ សល (VPBank)។ ខណៈពេលដែលការិយាល័យ ស៊ីអេអូ កំពុងធ្វើការប៉ាន់ប្រមាណទៅលើបណ្តឹងនេះ ក្រុមហ៊ុន ហ៊ាង អានយ៉ាឡាយ បានបង្ហាញឱ្យឃើញអំពីចំណាប់អារម្មណ៍ក្នុង ការចូលរួមជាថ្មីម្តងទៀតនៅក្នុងការដោះស្រាយវិវាទ។ អ្នក តំណាងសហគមន៍ក៏បានបង្ហាញឱ្យឃើញនូវចំណាប់អារម្មណ៍ ក្នុងការចូលរួមនៅក្នុងការដោះស្រាយវិវាទនេះដូចគ្នាដែរ។ យោងតាមគោលការណ៍ណែនាំស្តីពីប្រតិបត្តិការរបស់ ការិយាល័យ ស៊ីអេអូ បណ្តឹងនេះនឹងត្រូវដោះស្រាយដោយ មុខងារផ្នែកដោះស្រាយវិវាទ នៃការិយាល័យ ស៊ីអេអូ។ អាស្រ័យដោយគូភាគីនៅក្នុងកិច្ចសន្ទនា និង បញ្ហាសម្រាប់ ពិភាក្សា មានលក្ខណៈដូចគ្នាទាំងស្រុង ករណីទាំងពីរនេះនឹង ត្រូវដោះស្រាយរួមគ្នា តាមរយៈដំណើរការដោះស្រាយវិវាទតែ

មួយ។ ការផ្តល់របាយការណ៍អំពីករណីទាំងពីរនេះ នឹងត្រូវរួមបញ្ចូលគ្នាដោយស្មើគ្នា ចាប់ពីពេលនេះតទៅ។

## ក្រុមហ៊ុន ហ៊ែងអានយ៉ាឡាយ វិលត្រឡប់មកតុចរចារវិញ

កាលពីខែតុលា ឆ្នាំ២០១៩ ក្រុមហ៊ុនហ៊ែងអានយ៉ាឡាយ បានបង្ហាញអំពីចំណាប់អារម្មណ៍ ក្នុងការចូលរួមនៅក្នុងកិច្ចសន្ទនានេះវិញ។ ការិយាល័យ ស៊ីអេអូ បានជួបជាមួយក្រុមហ៊ុនហ៊ែងអានយ៉ាឡាយ និង សហគមន៍ដើមបណ្តឹងដាច់ដោយឡែកពីគ្នា កាលពីខែធ្នូ ឆ្នាំ២០១៩ ហើយភាគីទាំងសងខាងបានបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការដោះស្រាយបញ្ហាវិវាទដែលនៅសេសសល់ តាមរយៈដំណើរការដោះស្រាយវិវាទដែលរៀបចំឡើងដោយការិយាល័យ ស៊ីអេអូ។

## ជំហានបន្ទាប់

ការិយាល័យ ស៊ីអេអូ នឹងរៀបចំឱ្យមានជំនួបរវាងអ្នកតំណាងក្រុមហ៊ុន និង អ្នកតំណាងសហគមន៍ នៅដើមឆ្នាំថ្មី ដើម្បីពិភាក្សាអំពីជំហានបន្ទាប់។

## ឯកសារអំពីដំណើរការ

រាល់សេចក្តីថ្លែងការណ៍រួមទាំងអស់ និងឯកសារដទៃទៀតដែលពាក់ព័ន្ធនឹងករណីនេះ អាចរកបាននៅក្នុងគេហទំព័ររបស់ការិយាល័យ ស៊ីអេអូ៖ www.cao-ombudsman.org.

ទំព័រអំពីករណី The Cambodia: VEIL II-01/ ខេត្តរតនគិរី អាចចូលមើលបានដោយផ្ទាល់តាមរយៈគេហទំព័រ http://www.cao-ombudsman.org/cases/case_detail.aspx?id=212